# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៦៥

## ស្តីពី

## សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២២១ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ ៣ឆ្នាំ លើកទី៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# ប្រកាសបង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតសញ្ញាសក្តិ និង ឯកសណ្ឋាន សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២.-**

សញ្ញាសក្តិមាន សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និង សក្តិកន្ទាស់ ។

ឯកសណ្ឋានមានឯកសណ្ឋានផ្លូវការ និង ឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ ពិធីផ្លូវការផ្សេងៗ ។

**មាត្រា ៣.-**

ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់និមិត្តសញ្ញារបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់ដាក់នៅលើសក្តិចុងកអាវ សក្តិស្មានិង នៅលើសក្តិកន្ទាស់សម្រាប់ក្លាស់លើអាវបុរស ឬ នារី ឬ លើក្រមាពានារបស់នារីនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ២

## អំពីសញ្ញាសក្តិ

**មាត្រា ៤.-**

សញ្ញាសក្តិនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចតទៅ ÷

**១ . ក្របខ័ណ្ឌមន្ត្រីអភិបាល**

**ក . សក្តិចុងកអាវ**

សក្តិចុងកអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយនៅផ្នែកខាងដើម និង ខាងក្រោមតួសក្តិ មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស ។ នៅផ្នែកកណ្តាលរហូតដល់ចុងនៃតួសក្តិមានក្បាច់ភ្ញីទេសពណ៌មាស រចនាជាសន្លឹកផ្លែ និង ផ្កា ដែលតំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ហើយមានក្បាច់គ្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីទេស និងនិមិត្តសញ្ញា ពីផ្នែកខាងលើ និង ផ្នែកចំហៀងខាងមុខ ។ នៅជាយនៃតួសក្តិចុងកអាវ មានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ជាពីរជ្រុង គឺជ្រុងខាងដើម និង ជ្រុងខាងលើ ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់ និង ផ្នែកខាងចុងនៃសញ្ញាសក្តិចុងកអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-មានរាងជាប្រលេឡូក្រាម

-បណ្តោយ ប្រវែង ០៩.០០ សង់ទីម៉ែត្រ

-ទទឹង ប្រវែង ០៣.៥០ សង់ទីម៉ែត្រ

**ខ . សក្តិស្មា**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាសចំកណ្តាល ដែលរចនាជាសន្លឹក ផ្លែ និង ផ្កា តំណាងទូវដំណាំរូមផ្សំនៅកម្ពុជា ។ នៅពីខាងលើក្បាច់ភ្ញីទេស មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស ហើយនៅលើនិមិត្តសញ្ញានេះ មានឡេវរូបព្រះសង្ខារពណ៌មាសមួយ ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់-ទីម៉ែត្រ។ ឡេវ និមិត្តសញ្ញា និង ក្បាច់ភ្ញីទេសហ៊ុំព័ទ្ធជុំវិញដោយក្បាច់គ្របកឈូកពណ៌មាស ។ នៅជាយនៃតួសក្តិស្មាមានក្បាច់ជរជាយរចនាជាខ្សែពួរវេញពណ៌មាស ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន ០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។

**ខ្នាតសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-បាតក្រោម ប្រវែង ០៦.០០ សង់ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ០៤.៥០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោម ប្រវែង ១២.០០ សង់ទីម៉ែត្រ

**គ . សក្តិចុងដៃអាវ**

សក្តិចុងដៃអាវមានផ្ទៃកម្ចីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស ដែលរចនាជាសន្លឹក ផ្លែ និង ផ្កា តំណាងទូវដំណាំរូមផ្សំនៅកម្ពុជា ហើយមានក្បាច់គ្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីទេស នៅជាយផ្នែកខាងលើ និង ផ្នែកចំហៀងទាំងសងខាង ។ នៅជាយនៃតួសក្តិចុងដៃអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ហ៊ុំព័ទ្ធជាបីជ្រុង គឺនៅផ្នែកខាងលើ និង ផ្នែកចំហៀងទាំងសងខាង ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់នៃសញ្ញាសក្តិចុងដៃអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងដៃអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-មានរាងជាបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២.០០ សង់ទីម៉ែត្រ

-ទទឹង ប្រវែង ០៨.០០ សង់ទីម៉ែត្រ

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷**

-ឋានន្តរសក្តិឧត្តមអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១

-ឋានន្តរសក្តិវរអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរសក្តិអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យនេះ ។

**ឃ . សក្តិកន្លាស់**

សក្តិកន្លាស់សម្រាប់ក្លាស់លើអាវបុរស នារី ឬ លើក្រមាពាននារី សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល មានរាងពងក្រពើ កម្ពស់ ០៦.០០ សង់ទីម៉ែត្រ ទទឹង ០៥.០០ សង់ទីម៉ែត្រ ។

នៅផ្ទៃកកណ្តាលខាងក្នុងនៃសក្តិកន្លាស់មានផ្ទៃពណ៌ក្រហម និង មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស ។ នៅផ្ទៃកខាងក្រៅមានផ្ទៃពណ៌ខៀវព័ទ្ធពីខាងក្រៅរង្វង់និមិត្តសញ្ញា ដែលហៅថា " ហាមមណ្ឌល " ។ នៅផ្ទៃកខាងលើនៃហាមមណ្ឌលមានចារឹកអក្សរខ្មែរថា " **ព្រះរាជាណាចក្រកម្ពុជា** " ជាពណ៌មាស និង នៅផ្ទៃកខាងក្រោមមានចារឹកអក្សរខ្មែរថា" **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**" ជាពណ៌មាស ។ នៅចន្លោះអក្សរខ្មែរទាំងពីរនេះ មានក្បាច់ដកចន្ទនីពណ៌មាស ស្ថិតនៅសងខាងនៃហាមមណ្ឌល ។ នៅជាយខាងក្រៅនៃហាមមណ្ឌលហ៊ុំព័ទ្ធដោយក្បាច់គ្របកឈូក និង មានក្បាច់ចំណងមួយ ដែលរចនាដោយក្បាច់ភ្ញីទេសពណ៌មាស មានស្លឹកម្ខាង១ចំនួន ០៤ និងផ្លែ ម្ខាង១ចំនួន ០៣ ព័ទ្ធជុំវិញក្បាច់គ្របកឈូក ។

**២ . ក្របខ័ណ្ឌមន្ត្រីឧបការី**

សញ្ញាសក្តិ ( សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និង សក្តិកន្លាស់ ) សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានសណ្ឋាន រូបភាព និង មានការបែងចែកទៅតាមឋានន្តរសក្តិ ដូចសញ្ញាសក្តិមន្ត្រីក្របខ័ណ្ឌអភិបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី គឺពណ៌ប្រាក់ ។

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ៖**

-ឋានន្តរសក្តិនាយឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤

-ឋានន្តរសក្តិឧបការីដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥

-ឋានន្តរសក្តិឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦នៃព្រះរាជក្រឹត្យនេះ ។

**រូបគំនូរសក្តិកន្លាស់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ ។**

**៣ . សញ្ញាសក្តិសម្រាប់មន្ត្រីរាជការជានារី**

សក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវ សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីជានារី គឺដូចគ្នាគ្រប់ចំណុចទាំងអស់ទៅនឹងគ្រប់ឋានន្តរសក្តិសម្រាប់បុរសដែរ ខុសគ្នាតែពីទំហំប៉ុណ្ណោះគឺ ៖

-សក្តិចុងកអាវ : អាចមានទទឹងពី ៣ ទៅ ៣.៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌនារី

-សក្តិស្មា : អាចមានទំហំ ៨០% ឬ ៨៥% ឬ ៩០% នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

-សក្តិចុងដៃអាវ : អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី

## ជំពូកទី ៣

## អំពីឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៥.-**

ឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចខាងក្រោម ៖

**១ . ឯកសណ្ឋានផ្លូវការ**

**ក . ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ នៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ អាវនេះមានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ការពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ( ពណ៌មាសសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ពណ៌ប្រាក់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌឧបការី ) ដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ មានបិទឡេវរូបព្រះសង្ការចំនួន០៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ហើយឡេវនីមួយៗមានអង្កត់ផ្ចិតប្រវែង ០២,៥០ សង់ទី ម៉ែត្រ ។

-ខោជើងវែងពណ៌ ស គចង្កេះ ក្ដឹបកក្រោយខាងឆ្វេង ០២ ខាងស្តាំ ០២ ហោប៉ៅចំហៀងនៅសងខាង និងហោប៉ៅចោះក្រោយ ០១ នៅខាងស្តាំ ។

-ស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ។

**ខ . ចំពោះនារី**

-អាវជីបរាង ពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ កត្រង់ គ្មានផែកខ្នង មានឡេវមុខរូបព្រះសង្ការពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ចំនួន ០៥ មានអង្កត់ផ្ចិតប្រវែង ០២,៥០សង់ទីម៉ែត្រ ។ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវតាមឋានន្តរសក្តិ ។ នៅលើស្មាមានបន្ទះសម្រាប់ដាក់សក្តិមួយគូ មានហោប៉ៅចោះចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដោយមានគម្របរាងស្លឹកពោធិ៍ ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ។ ដៃអាវវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

-សំពត់សំឡយអំពីផាមួងពណ៌ខៀវ មានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី ១០ ទៅ ១៥ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌ និង កម្ពស់ ។

-ស្បែកជើងអេស្កាប៉ាង ឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

**រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។**

**២ . ឯកសណ្ឋានប្រពៃណីជាតិ**

**ក . ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំគ្មានផែកខ្នង ។ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ នៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ អាវនេះមានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ មានបិទឡេវរូបព្រះសង្ហារ ចំនួន០៧ ពណ៌មាស ហើយឡេវនីមួយៗមានអង្កត់ផ្ចិតប្រវែង ០២,៥០ សង់ទីម៉ែត្រ។

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និង ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

**ខ . ចំពោះនារី**

-អាវជីបរាង ពណ៌ " ស " ដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិតប្រវែង ០១,៥០ សង់ទីម៉ែត្រ និង ត្រង់ស្មាឃ្លាតពីគល់កប្រមាណ ០២,៥០ ទៅ ០៣,០០ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី ។ អាវនេះ គ្មានសក្តិស្មា និង សក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមក្របខ័ណ្ឌ និងឋានន្តរសក្តិ។

-ពានាក្រមាពណ៌តាមសំពត់ ។ សាច់ក្រមា ដែលធ្វើអំពីសូត្រ មានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬ ពានាក្រមាពណ៌ស៊ីនួន ឬ តាមពិធីការ កំណត់ ហើយនៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង ត្រូវពាក់ "សក្តិកន្ទាស់ " ជាសញ្ញាសម្គាល់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ។

-សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និង ពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

-កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ( មិនឱ្យស្ពាយទេ ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

**រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។**

**មាត្រា ៦.-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និង ពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ឬ តាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន។

-ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និង សាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬ ក្នុងវត្តអារាម ឬ ទីកន្លែងផ្សេងៗ ត្រូវបានកំណត់ឱ្យប្រើសម្រាប់តែមន្ត្រីរាជការក្របខ័ណ្ឌអភិបាល ដែលមានឋានន្តរសក្តិឧត្តមអភិបាល ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ក៏ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ឬ ក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី ៤
## របបកំណត់សញ្ញាសក្តិ និង ឯកសណ្ឋាន

**មាត្រា ៧.-**

សញ្ញាសក្តិ ឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ និង សម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានផ្តល់ជូនដល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីមួយសម្រាប់ក្នុងម្នាក់ៗ សម្រាប់រយៈពេល ០៣ ឆ្នាំ ។

ការចំណាយលើសញ្ញាសក្តិ ឯកសណ្ឋានគ្រប់ប្រភេទ និង សម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ជាបន្ទុកថវិការដ្ឋ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៦០៨.៣៨៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦

លេខ : ០០៤ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

**អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ**

[illegible]

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិឧត្តមអភិបាល (ពណ៌មាស)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិអភិបាល (ពណ៌មាស)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិអភិបាល (ពណ៌មាស)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិនាយឧបការី (ពណ៌ប្រាក់)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិឧបការីដើមខ្សែ (ពណ៌ប្រាក់)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិឧបការី (ពណ៌ប្រាក់)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សក្តិកន្លាស់



សម្រាប់ក្របខ័ណ្ឌអភិបាល ពណ៌មាស



សម្រាប់ក្របខ័ណ្ឌឧបការី ពណ៌ប្រាក់

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## ឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី



ឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

# ឯកសណ្ឋានប្រពៃណីជាតិ សម្រាប់បុរស និង នារី

## (ឋានន្តរសក្តិឧត្តមអភិបាលនៃក្របខ័ណ្ឌអភិបាល)

